K02205
TSL 00014

# ប្រវត្តិរូបរបស់ជនពាក់ខ្លួន "ក្បត់ស៊ីស្ប"

## ឈ្មោះ សរិត . ខែម

I បញ្ហាផ្ទាល់ខ្លួន

១ - ឈ្មោះ សរិត . ខែម អាយុ ២៥ ឆ្នាំ សញ្ជាតិ ខ្មែរ

២ - កំរិត វប្បធម៌ រៀននៅវិទ្យាល័យ តាខ្មៅ ថ្នាក់ ទី ៣

៣ - ធ្វើ ម្ចង់ជូរ សិស្ស ខែ ១ ដល់ខែ ៧ ឆ្នាំ ៧១ និងពីខែ ៩ ដល់ ខែ ៨ ឆ្នាំ ៧២ សរុប ១៣ ខែ នៅយាមសាលា គ្មាន ឋានៈអ្វី ទេ ហើយមិនបានទៅសមរភូមិ

៤ - ទីលំនៅ មុន ១៨. ៣.៧០ នៅ ភូមិ ស្ទឹងជ្រៅ ឃុំ ចាក់អង្រែ ភ្នំពេញ ក្រោយ ១៨. ៣.៧០ នៅ កន្លែង ដដែល

- ក្រោយ ១៧. ៤. ៧៥ ទៅនៅ ភូមិ តាជា ឃុំ តាខ្មៅ ស្រុក ១៥៤ តំបន់ ១៥

II បញ្ហាឪពុកម្តាយ បង្កើត

១ - ឪពុកឈ្មោះ សរិត . យុត អាយុ ៥១ ឆ្នាំ ជាតិ ខ្មែរ

- ម្តាយឈ្មោះ អ៊ុច . រិន អាយុ ៤៧ ឆ្នាំ

២ - ទីលំនៅ មុននិងក្រោយ ១៨. ៣.៧០ នៅភូមិ ស្ទឹងជ្រៅ ឃុំ'ចាក់អង្រែ ស្រុកភ្នំពេញ

- ក្រោយ ១៧ . ៤. ៧០ ជំលៀសទៅនៅ ភូមិ ព្រែកតាជោ ឃុំ តាខ្មៅ ស្រុក ១៥៤ តំបន់១៥

៣ - របរកស៊ី មុន និងក្រោយ ១៨. ៣.៧០ ធ្វើ ចំការ

III បញ្ហាបងប្អូន បង្កើត

- មានបងប្អូន ៣ នាក់

១ - បងស្រី ឈ្មោះ សរិត . សារឿន អាយុ ៣០ ឆ្នាំ មានប្តី មានកូន ៣ ធ្វើចំការ

២ - ទីលំនៅ មុននិង ក្រោយ ១៨. ៣. ៧០ នៅ ភូមិ ស្ទឹងជ្រៅ ឃុំ ចាក់អង្រែ ស្រុក ភ្នំពេញ

- ក្រោយ ១៧. ៤. ៧៥ ជំលៀស ទៅនៅ ភូមិ តាមូល ឃុំ ព្រែកកពិល ស្រុក ១៥៤ តំបន់ ១៥

២ - គឺ ឈ្មោះ សរិត . ខែម

៣ - សរិត . សារុន អាយុ ១៨ ឆ្នាំ នៅរៀន នៅក្នុង បន្ទុក ឪពុកម្តាយ រហូតមកដល់សព្វថ្ងៃនេះ

IV ចម្លើយ

- គោលបំណង ទៅ ភូមិ តាជា ឃុំ តាខ្មៅ នៅម៉ោង ៧ យប់ នៅ ថ្ងៃទី ៣០ . ៧. ៧៥ ជាមួយបងប្អូនជីដូន មួយ ឈ្មោះ សរិត . ឃន លំនៅទៅ ស្ទឹងជ្រៅ ដើម្បី មើលភូមិ កំណើត ម្យ៉ាងទៀតដោយមានការខ្វះខាតខ្លាំងពេក ក៏ ដាច់ចិត្តនាំគ្នាទៅ ទាំងយប់

- ឃាត់ខ្លួនទុក កាលពីថ្ងៃទី ៣០. ៧.៧៥

ធ្វើនៅថ្ងៃទី ១០ ខែ ៨ ឆ្នាំ ៧៥

ជ. គណៈបញ្ជាការវរៈសេនាតូចតូច

ពិន